ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ

លេខ: ០២៩៨ ផក

# លិខិតជូនពរ

យើងខ្ញុំទាំងអស់គ្នា ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្នុងក្រសួងផែនការទាំងមូល

**សូមគោរពជូន**

**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។**

ក្នុងឱកាសដ៏ថ្លៃថ្លា នៃទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ គ.ស.២០២០នេះ យើងខ្ញុំទាំងអស់គ្នាជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងផែនការ សូមសម្តែងនូវមនោសញ្ចេតនា គោរព ស្រឡាញ់ ប្រកបដោយកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅជាទីបំផុត ជូនចំពោះ **សម្តេច** ក្នុងការដឹកនាំមាតុភូមិ និងប្រជាជនកម្ពុជាឆ្ពោះទៅរកសុខសន្តិភាព ការអភិវឌ្ឍ និងភាពចម្រើនរុងរឿង។

យើងខ្ញុំទាំងអស់គ្នាជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងផែនការ សូមប្រសិទ្ធិពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ **សម្តេចពិជ័យសេនា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ បានសម្រេចជោគជ័យដ៏ត្រចះត្រចង់ ក្នុងបេសកកម្ម កសាង និងអភិវឌ្ឍន៍ប្រទេសជាតិទៅអនាគត។

យើងខ្ញុំទាំងអស់គ្នាជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងផែនការ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រៃយ៍ គុណកែវទាំងបី និងវត្ថុស័ក្តិសិទ្ធក្នុងលោក សូមតាមជួយបីបាច់ថែរក្សាការពារ **សម្តេច និងលោកជំទាវ** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី ជាទីស្រលាញ់ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំង៤ប្រការ គឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចពិជ័យសេនា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ទទួលបាននូវជោគជ័យថ្មីៗថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដើម្បីដឹកនាំមាតុភូមិ និងប្រជាជនកម្ពុជា ឆ្ពោះទៅរកភាពរីកចម្រើនរុងរឿង និងមានសុខសន្តិភាពជារៀងរហូតតទៅ។

សូម **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** មេត្តាទទួលនូវសព្ទសាធុការពរដ៏ថ្លៃថ្លា និងទទួលនូវគារវកិច្ចគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០

**តំណាងមន្ត្រីរាជការក្រសួងផែនការ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**